ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# មេរៀននៃវគ្គបណ្តុះបណ្តាល




ថ្ងៃពុធ ០១កើត ខែបុស្ស ឆ្នាំរការ នព្វស័ក ព.ស ២៥៦១

ថ្ងៃទី ១៨ ខែ ធ្នូ គ.ស ២០១៧

RECOFTC
THE CENTER FOR
PEOPLE AND FORESTS

# មាតិកា


1. **សេចក្តីថ្លែងអំណរគុណ** ........ 3
.2 **អារម្ភកថា** ........ 3
3. **សារៈសំខាន់នៃគម្រោងឥណទានគាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍** ........ 5
4. **យុទ្ធសាស្រ្ត និងដំណើរការបង្កើត** ........ 6
4.1 តួនាទីរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ........ 6
4.2 តួនាទីរបស់ក្រុមឥណទាន ........ 7
4.3 ជំហានការងារ និងសកម្មភាពក្នុងការបង្កើតក្រុមឥណទាន/សន្សំសហគមន៍ព្រៃឈើ ........ 7
5. **លក្ខខណ្ឌសំខាន់ៗរបស់លក្ខន្តិកៈក្រុមឥណទាន** ........ 8
6. **មេរៀន និងបទពិសោធន៍នៃគម្រោងឥណទាន** ........ 9
7. **ឧបសម្ព័ន្ធ** ........ 10
7.1 ឧបសម្ព័ន្ធ ១៖ ពាក្យសុំចូលជាសមាជិកក្រុមឥណទានសហគមន៍ព្រៃឈើ ........ 10
7.2 ឧបសម្ព័ន្ធ ២៖ លក្ខន្តិកៈស្តីពីការគ្រប់គ្រងប្រាក់ឥណទានសហគមន៍ព្រៃឈើ ........ 11
7.3 ឧបសម្ព័ន្ធ៣៖ ទម្រង់កិច្ចព្រមព្រៀងខ្ចីប្រាក់ ........ 18
7.4 ឧបសម្ព័ន្ធ ៤៖ ទម្រង់សំណើខ្ចីប្រាក់របស់សមាជិក ........ 19
7.5 ឧបសម្ព័ន្ធ ៥៖ តារាងកាលវិភាគបង់ប្រាក់ប្រចាំខែ ........ 20
7.6 ឧបសម្ព័ន្ធ ៦៖ សៀវភៅកត់ត្រាការខ្ចីប្រាក់ ........ 21
7.7 ឧបសម្ព័ន្ធ ៧៖ សៀវភៅបេឡា ........ 23
7.8 ឧបសម្ព័ន្ធ ៨៖ ទម្រង់របាយការណ៍ហិរញ្ញវត្ថុ ........ 24

## 1. សេចក្តីថ្លែងអំណរគុណ

កម្រងមេរៀនស្តីពីគម្រោងឥណទានសហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ការអនុវត្តផែនការ គ្រប់គ្រងព្រៃសហគមន៍នេះត្រូវបានរៀបចំឡើងដោយក្រុមការងារ នៃកម្មវិធីប្រចាំប្រទេសរបស់ RECOFTC កម្ពុជា ដោយមានការគាំទ្រពីគម្រោង ដៃគូវិស័យព្រៃឈើ និងផលផល PaFF គម្រោងនិរន្តរភាពនៃការគ្រប់គ្រងសហគមន៍ព្រៃឈើតាមរយៈការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ SMCF-ICFMP និងគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើ ខេត្តកំពង់ធំ។ លើសពីនេះទៅទៀតការរៀបចំកម្រងមេរៀននេះធ្វើឡើងដោយផ្អែកលើលទ្ធផលនៃការអនុវត្តផ្ទាល់របស់ សហគមន៍ព្រៃឈើព្រៃក្បាលបី ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ។

កម្មវិធីប្រចាំប្រទេសរបស់ RECOFTC កម្ពុជា សូមថ្លែងអំណរគុណដល់អង្គការ និងទីភ្នាក់ងារផ្តល់ជំនួយដែលបានគាំទ្រដល់គម្រោង PaFF និង SMCF-ICFMP និងក្រុមការងារនៃគម្រោងដែលបានសម្របសម្រួលការសាកល្បងគម្រោងឥណទានសហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ និងប្រមូលចងក្រងនូវបទពិសោធន៍ និងមេរៀនល្អៗ ដើម្បីចងក្រងជាកម្រងមេរៀននេះឡើង។

សូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើព្រៃក្បាលបី សមាជិកសហគមន៍ព្រៃឈើដែលបានចូលរួមយ៉ាងសស្រាក់សស្រាំធ្វើឲ្យគម្រោងឥណទានមានការរីកចម្រើន និងចែករំលែកនូវបទពិសោធន៍ជោគជ័យទៅសហគមន៍ផ្សេងៗ ទៀត តាមរយៈសិក្ខាសាលា និងជាពិសេសការរៀបចំកម្រងមេរៀនស្តីពីគម្រោងឥណទានសហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ នេះឡើង។

សូមថ្លែងអំណរគុណដល់អាជ្ញាធរភូមិ ឃុំ រដ្ឋបាលព្រៃឈើមូលដ្ឋាន ដែលបានចូលរួមសម្របសម្រួល និងគាំទ្រដល់ដំណើរការគម្រោងឥណទានសហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ នៅសហគមន៍ព្រៃឈើព្រៃក្បាលបី ឲ្យទទួលបានជោគជ័យ។

## 2. អារម្ភកថា

ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់តំណាងសហគមន៍ព្រៃឈើដែលបានស្នើសុំជាច្រើនដង ឲ្យជួយគាំទ្រទាំងការងារបច្ចេកទេស និងថវិកាក្នុងការបង្កើតឥណទានសហគមន៍ព្រៃឈើ ជាពិសេសនៅខែកុម្ភៈ ឆ្នាំ២០១៤ ក្នុងបទបង្ហាញរបស់គ.គ.ស ទៅកាន់អ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងវេទិកាជាតិលើកទី១ ស្តីពីមនុស្សនិងព្រៃឈើ លោកតន ទីន តំណាង គ.គ.ស ត្រពាំងរូង ក្នុងខេត្តកំពង់ធំ បានសង្កត់ធ្ងន់ទៅលើសំណើសុំបង្កើតក្រុមឥណទានសហគមន៍ព្រៃឈើ។ RECOFTC តាមរយៈកម្មវិធីអ្នកហាត់ការថ្នាក់តំបន់ បានគាំទ្រអ្នកហាត់ការថ្នាក់ជាតិម្នាក់ឲ្យសម្របសម្រួលរៀបចំបង្កើត គម្រោងឥណទានសហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍។

សហគមន៍ព្រៃឈើព្រៃក្បាលបី ឃុំទីពោ ស្រុកសន្ទុក ជាសហគមន៍ព្រៃឈើមួយ ក្នុងចំណោមសហគមន៍ព្រៃឈើ ៥ នៅក្នុងខេត្តកំពង់ធំដែលត្រូវបានជ្រើស ឲ្យសាកល្បងអនុវត្តគម្រោងឥណទានសហគមន៍ព្រៃឈើ ដើម្បី

គាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍។ សហគមន៍ព្រៃឈើព្រៃក្បាលបីបានធ្វើការសាកល្បង គម្រោងឥណទានដើម្បីគាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍នៅឆ្នាំ២០១៥ ដោយចាប់ផ្តើមពីការដាក់ទុន ចំនួន ១000ដុល្លា ស្មើនឹង ៤លានរៀល បច្ចុប្បន្ន គិតត្រឹម ខែវិច្ឆិកា ឆ្នាំ២០១៧ គម្រោងឥណទាននេះកំពុងដំណើរការដោយទទួលបានលទ្ធផលគួរជាទីពេញចិត្ត ដោយសហគមន៍មានទុនសរុប រហូតដល់ជាង ១៦លានរៀល ស្មើនឹង ជាង៤000ដុល្លា។

គោលបំណងរួមនៃគម្រោងឥណទាននេះ គឺដើម្បីបង្កើតជាប្រភពថវិកាសម្រាប់សមាជិកធ្វើការវិនិយោគទៅលើសកម្មភាពចិញ្ចឹមជីវិត និងជាប្រភពចំណូលដល់ស្ថាប័នសហគមន៍ព្រៃឈើ ដើម្បីផ្គត់ផ្គង់ថវិកាគាំទ្រដល់ការអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍។ វាជាការលើកទឹកចិត្តដល់សមាជិកសហគមន៍ព្រៃឈើឲ្យចូលរួមក្នុងសកម្មភាពគ្រប់គ្រង និងការពារសហគមន៍ព្រៃឈើព្រោះគេអាចទទួលបានទុនតាមរយៈឥណទានសហគមន៍ព្រៃឈើក្នុងការពង្រីករបរចិញ្ចឹមជីវិត។ មានគម្រោងឥណទានមួយចំនួនបង្កើតឡើង និងកំពុងមានដំណើរការ ប៉ុន្តែមិនទាន់មានគោលការណ៍នៃការវិភាជន៍ថវិកា សម្រាប់ផ្សារភ្ជាប់ទៅនឹង ការអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍ទេ។

កម្រងមេរៀនស្តីពីគម្រោងឥណទានសហគមន៍ព្រៃឈើ ដើម្បីគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍នេះ ត្រូវបានចងក្រងដោយផ្អែកលើលទ្ធផលនៃការអនុវត្តផ្ទាល់នៅក្នុងសហគមន៍ព្រៃឈើព្រៃក្បាលបី ចាប់តាំងពីដំណើរការបង្កើតនៅក្នុងឆ្នាំ ២០១៥ ការដំណើរការគម្រោងចាប់តាំងពីពេលបង្កើត និងការកែសម្រួលដំណើរការនានា ដោយយោងតាមការឆ្លុះបញ្ចាំង ទៅលើទិដ្ឋភាព និងតម្រូវការជាក់ស្តែងនៅក្នុងសហគមន៍។

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើព្រៃក្បាលបី រួមជាមួយគណៈកម្មការក្រុមឥណទាននៃសហគមន៍ព្រៃឈើព្រៃក្បាល និងប្រើប្រាស់កម្រងមេរៀនដើម្បីជាមូលដ្ឋានសម្រាប់បង្រៀនដល់សហគមន៍ព្រៃឈើ ដែលមានចំណាប់អារម្មណ៍ក្នុងការបង្កើតគម្រោងឥណទាន ឬចង់កែសម្រួលគម្រោងឥណទានដែលមានស្រាប់ដើម្បីវិភាជថវិកាគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍។

## 3. សារៈសំខាន់នៃគម្រោងឥណទានគាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍

កម្មវិធីសហគមន៍ព្រៃឈើជាតិ គឺជាកម្មវិធីទី៤ នៃកម្មវិធីព្រៃឈើជាតិកម្ពុជា ២០១០-២០២៩ ដែល សម្របសម្រួល និងអនុវត្តដោយរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ គោលបំណងសំខាន់នៃកម្មវិធីព្រៃឈើជាតិ គឺដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃប្រកបដោយនិរន្តភាពដោយសហគមន៍មូលដ្ឋាន។

ការអភិវឌ្ឍសហគមន៍ព្រៃឈើ ពឹងអាស្រ័យទៅលើប្រភពថវិកាពីខាងក្រៅ ដែលជារឿយៗ តាមរយៈគម្រោងជំនួយអន្តរជាតិ សម្រាប់ អនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍ ដែលរួមមានសកម្មភាព ស្តារព្រៃឈើឡើងវិញ កិច្ចការពារព្រៃឈើសហគមន៍ ការផ្សព្វផ្សាយ ការគ្រប់គ្រង និងដោះស្រាយទំនាស់ជាដើម។ ទោះជាយ៉ាងណាក៏ដោយ ការគាំទ្រថវិកាដែលផ្តល់តាមរយៈគម្រោងមានពេលវេលាកំណត់ នៅពេលដែលសកម្មភាពនៃការអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍មិនមានពេលវេលាបញ្ចប់ឡើយ។ ដើម្បីបន្តការអនុវត្តន៍សកម្មភាពនៃផែនការគ្រប់គ្រងព្រៃសហគមន៍ ឲ្យទទួលបានជោគជ័យ និងដើម្បីចូលរួមចំណែកសម្រេចនូវគោលបំណងនៃកម្មវិធីសហគមន៍ព្រៃឈើជាតិ សហគមន៍ព្រៃឈើត្រូវការប្រភពចំណូលដើម្បីគាំទ្រសកម្មភាពនៃការគ្រប់គ្រងព្រៃសហគមន៍។ ដូចបានដឹងហើយថាសហគមន៍ព្រៃឈើភាគច្រើន មានធនធានព្រៃឈើរេចរឹល ដែលមិនអាចបម្រើផលប្រយោជន៍សេដ្ឋកិច្ចដល់សហគមន៍នាពេលបច្ចុប្បន្ន ដូចនេះសហគមន៍ត្រូវការទុនសម្រាប់ការអភិវឌ្ឍជីវភាពរស់នៅ។ ហេតុដូចនេះ ក្នុងដំណាក់កាលបច្ចុប្បន្ន សហគមន៍ព្រៃឈើ មិនអាចរកចំណូលពីធនធានព្រៃសហគមន៍ សម្រាប់គាំទ្រដល់សកម្មភាពអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ របស់ខ្លួនបានទេ ព្រមទាំងសមាជិកមិនអាចស្វែងរក និងប្រមូលផល និងអនុផលព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតគ្រប់គ្រាន់នៅឡើយទេ។ ការគ្រប់គ្រង និងជម្រើសគាំទ្រមូលនិធិនានាត្រូវបានពិចារណា ដើម្បីឲ្យសហគមន៍ព្រៃឈើ ដំណើរការស្របតាមកម្មវិធីព្រៃឈើជាតិ អាចចូលរួមចំណែកការកាត់បន្ថយភាពក្រីក្រ។

ការបង្កើតឥណទានសហគមន៍ព្រៃឈើនៅតាមសហគមន៍ព្រៃឈើនិមួយៗ គឺជាប្រភពនៃថវិកាសម្រាប់សមាជិកធ្វើការវិនិយោគទៅលើសកម្មភាពចិញ្ចឹមជីវិត ហើយក៏ជាប្រភពចំណូលដល់សហគមន៍ព្រៃឈើ ដើម្បីផ្គត់ផ្គង់ថវិកាគាំទ្រដល់ការអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍។ លើសពីនេះទៅទៀតវាជាការលើកទឹកចិត្តដល់សមាជិកសហគមន៍ព្រៃឈើឲ្យចូលរួមក្នុងសកម្មភាពគ្រប់គ្រង និងការពារសហគមន៍ព្រៃឈើព្រោះគេអាចទទួលបានទុន តាមរយៈឥណទានសហគមន៍ព្រៃឈើក្នុងការពង្រីកមុខរបរចិញ្ចឹមជីវិត។

គម្រោងឥណទានសហគមន៍ព្រៃឈើដើម្បី គាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍មានគោលបំណងដើម្បីពង្រឹងស្ថាប័នសហគមន៍ព្រៃឈើ និងលើកទឹកចិត្តឲ្យមានការចូលរួមអនុវត្តន៍ផែនការគ្រប់គ្រងព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។

## 4. យុទ្ធសាស្ត្រ និងដំណើរការបង្កើត

គម្រោងនឹងផ្តល់ថវិកាសម្រាប់ជាទុនក្នុងការធ្វើឥណទានសហគមន៍ព្រៃឈើ ដោយផ្តល់ថវិកាតាមរយៈមូលនិធិអភិវឌ្ឍន៍សហគមន៍ព្រៃឈើ។ ថវិកានេះត្រូវគ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើនៅក្រោមលក្ខខណ្ឌដែលមានការឯកភាព ដឹងឮពីសមាជិកសហគមន៍ព្រៃឈើ និងមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន (មេភូមិ និងមេឃុំ)។ សមាជិកសហគមន៍ព្រៃឈើ ដែលចាប់អារម្មណ៍ចង់ខ្ចីប្រាក់ពីមូលនិធិអភិវឌ្ឍសហគមន៍ព្រៃឈើយកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅ ត្រូវចូលរួមចងក្រងជាក្រុម និងបោះឆ្នោតជ្រើសតាំងគណៈកម្មការក្រុមឥណទាន/ក្រុមសន្សំ និងបង្កើតជាលក្ខន្តិកៈឥណទានសម្រាប់ក្រុមអនុវត្ត។ លក្ខន្តិកៈឥណទាននេះត្រូវមានការឯកភាពពីគណកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន។ ការប្រាក់ពីឥណទានសហគមន៍ព្រៃឈើ ត្រូវបានយកទៅប្រើប្រាស់សម្រាប់សកម្មភាពអនុវត្តផែនការគ្រប់គ្រងរួមមាន ការដាំព្រៃឈើឡើងវិញ ការការពារព្រៃឈើ ការបង្កើនទុន និងការផ្លាស់ប្តូរជម្លោះវិជ្ជមាន ការចូលរួមទាំងនេះគឺជាផ្នែកសំខាន់នៃគម្រោងឥណទានសហគមន៍ព្រៃឈើ។




### *4.1 តួនាទីរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ*

គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រូវពិនិត្យទៅលើលក្ខន្តិកៈសហគមន៍ព្រៃឈើ ជំពូក៨ ស្តីពីហិរញ្ញវត្ថុសហគមន៍ព្រៃឈើ និងឯកសារ ដើម្បីរៀបចំលក្ខខណ្ឌបន្ថែម សម្រាប់គម្រោងឥណទាន រួមទាំងអត្រាការប្រាក់ ការវិភាជថវិកាសម្រាប់សកម្មភាពអភិវឌ្ឍសហគមន៍ព្រៃឈើ។ គ.គ.ស ត្រូវពិនិត្យទៅលើលក្ខន្តិកៈក្រុមឥណទានដើម្បីធានាដល់ការសងប្រាក់តាមពេលកំណត់ អត្រាការប្រាក់សមរម្យ និងសុំការទទួលស្គាល់លើលក្ខន្តិកៈ

ក្រុមឥណទានពីអាជ្ញាធរពាក់ព័ន្ធ ដើម្បីជាសាក្សី និង ចូលរួមដោះស្រាយវិវាទនានាដែលអាចកើតមានឡើងក្នុងដំណើរការគម្រោងឥណទាន។

គ.គ.ស ត្រូវគ្រប់គ្រងចំណូលនៃការប្រាក់ដោយឯកភាពទៅលើអត្រានៃការ វិភាជន៍ថវិកា សម្រាប់គាំទ្រសកម្មភាពគ្រប់គ្រងសហគមន៍ព្រៃឈើ និងបង្កើនទុនប្រាក់កម្ចី (% សម្រាប់ការគ្រប់គ្រង និង%សម្រាប់បង្កើនទុនឲ្យសមាជិកខ្ចី)។

## *4.2 តួនាទីរបស់ក្រុមឥណទាន*

សមាជិក ស.ព ដែលចាប់អារម្មណ៍ត្រូវចូលរួមចងក្រងជាក្រុម និងបោះឆ្នោតជ្រើសតាំងគណៈកម្មការក្រុមឥណទាន/ក្រុមសន្សំ និងបង្កើតជាលក្ខន្តិកៈឥណទានសម្រាប់ក្រុមអនុវត្ត។ សហគមន៍ព្រៃឈើមួយអាចមានក្រុមឥណទាន/ក្រុមសន្សំ ១ក្រុម ឬ លើសពីនេះ អាស្រ័យលើការស្ម័គ្រចិត្តចូលជាសមាជិកក្រុម។ ក្រុមនិមួយៗមានសមាជិកពី១០ទៅ២៥នាក់ និងដឹកនាំដោយគណៈកម្មការ៣រូប មានប្រធានក្រុម អនុប្រធានក្រុម និងហិរញ្ញិក។ ក្រុមឥណទាននឹងខ្ចីប្រាក់ពីមូលនិធិអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ក្រោមកិច្ចសន្យាជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដើម្បីដំណើរការគម្រោងឥណទាន ដោយឯកភាពទៅលើអត្រាការប្រាក់ និងធានាដល់ការសងប្រាក់តាមរយៈពេលកំណត់។

## *4.3ជំហានការងារ និងសកម្មភាពក្នុងការបង្កើតក្រុមឥណទាន/សន្សំសហគមន៍ព្រៃឈើ*

***<u>ជំហានការងារ និងសកម្មភាពក្នុងការបង្កើតក្រុមឥណទាន/សន្សំសហគមន៍ព្រៃឈើ</u>***

| ជំហាន និងសកម្មភាព | លទ្ធផលរំពឹងទុក |
|---|---|
| **ជំហាន១: ផ្សព្វផ្សាយទស្សនទានទៅដល់សមាជិកសហគមន៍** | |
| - គ.គ.ស និងក្រុមការងារ ផ្សព្វផ្សាយទស្សនៈទាននៃគម្រោងឥណទានសហគមន៍ព្រៃឈើ ទៅដល់សមាជិក សហគមន៍ ដើម្បីជ្រើសរើស សមាជិកក្រុមឥណទាន។ | - សមាជិក ស.ព យល់ដឹងពីអត្ថប្រយោជន៍នៃគម្រោងឥណទាន |
| **ជំហាន២: ការបង្កើតក្រុមឥណទាន** | |
| - គ.គ.ស ចុះឈ្មោះសមាជិកក្រុមឥណទាន<br>- បោះឆ្នោតជ្រើសរើសគណៈកម្មការឥណទាន/ក្រុមសន្សំ(សមាជិកគ.គ.ស ឬសមាជិកក្រុមត្រូវបានជ្រើសរើស។ | - ក្រុមឥណទាន/សន្សំប្រាក់សហគមន៍ព្រៃឈើត្រូវបានបង្កើតឡើង និងមានការទទួលស្គាល់ដោយគ.គ.ស និងមេឃុំ។ |
| **ជំហាន៣:ការបង្កើតលក្ខន្តិកៈក្រុមឥណទាន** | |

| | |
|---|---|
| រៀបចំលក្ខន្តិកៈគម្រោងឥណទានសហគមន៍ព្រៃឈើដើម្បីគាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍។ | លក្ខន្តិកៈក្រុមឥណទាន ត្រូវបានឯកភាព និងយល់ព្រមចុះហត្ថលេខាទទួលស្គាល់ដោយគ.គ.ស និង មេឃុំ។ |
| **ជំហាន៤:ការកសាងសមត្ថភាពដល់គណៈកម្មការឥណទាន/គណៈកម្មការក្រុមសន្សំ និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្ត** | |
| វគ្គបណ្តុះបណ្តាលស្តីពី:<br>○ ការគ្រប់គ្រងហិរញ្ញវត្ថុ<br>○ របាយការណ៍ហិរញ្ញវត្ថុ<br>○ ការទុកដាក់ឯកសារ | គណៈកម្មការឥណទាន/គណៈកម្មការក្រុមសន្សំ មានសមត្ថភាពក្នុងការគ្រប់គ្រង / ចាត់ចែងថវិកាសន្សំ |
| **ជំហាន៥:ដាក់ប្រាក់ទៅក្នុងមូលនិធិអភិវឌ្ឍន៍សហគមន៍ព្រៃឈើ** | |
| **ជំហាន៦:ការអនុវត្តន៍ និងការត្រួតពិនិត្យលើឥណទានខ្នាតតូចសហគមន៍ព្រៃឈើ** | |
| គណៈកម្មការឥណទាន/គណៈកម្មការក្រុមសន្សំ ជូនដំណឹងអំពីថវិកាដែលមានសម្រាប់សមាជិកក្រុមដាក់ពាក្យខ្ចីប្រាក់។ | ចំនួននៃសមាជិកក្រុមបានដាក់ពាក្យខ្ចីប្រាក់។ |

## 5. លក្ខខណ្ឌសំខាន់ៗរបស់លក្ខន្តិកៈក្រុមឥណទាន

ការរៀបចំ ឬបង្កើតលក្ខន្តិកៈគម្រោងឥណទាន គឺជាជំហានទី៣ នៃដំណើរការបង្កើត គណៈកម្មការឥណទានត្រូវសហការជាមួយ គ.ស.គ ដើម្បីរៀបចំលក្ខន្តិកៈ ក្នុងនោះលក្ខន្តិកៈគម្រោងឥណទាននេះ ត្រូវគ្របដណ្តប់នូវបទប្បញ្ញត្តិសំខាន់មានដូចជា៖

- អ្នកណាខ្លះអាចមានសិទ្ធិចូលជាសមាជិក និងចំនួននៃសមាជិក
- និតិវិធីនៃការខ្ចីប្រាក់
- ទឹកប្រាក់អតិបរិមាសម្រាប់ឲ្យសមាជិកខ្ចីបាន
- អត្រាការប្រាក់ប៉ុន្មាន និង រយៈពេលខ្ចី
- កម្ចីត្រូវបានប្រើប្រាស់ក្នុងគោលបំណងអ្វី
- វត្ថុបញ្ចាំ
- និតិវិធីនៃការសម្រេចចិត្ត ការកែប្រែលក្ខខណ្ឌ
- ការធ្វើរបាយការណ៍
- ការកំណត់នូវវិន័យ ឬទោសទណ្ឌនានាសម្រាប់ការរំលោភបំពានលើលក្ខន្តិកៈ ឬមិនសងប្រាក់កម្ចី ឬសងមិនទាន់ពេល វេលា
- ការបែងចែកផលប្រយោជន៍ដែលទទួលបានពីអត្រាការប្រាក់ក្នុងនោះត្រូវបានវិភាជជាបីផ្នែក៖

- ផ្នែកទី ១ សម្រាប់ដាក់ចូលមូលនិធិអភិវឌ្ឍសហគមន៍ព្រៃឈើ ដែលក្នុងនោះត្រូវបែងចែកជាពីរចំណែក គឺការបង្កើនទុនឥណទាន និងការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍
- ផ្នែកទី២ សម្រាប់ជាភាគលាភរបស់គណៈកម្មការក្រុមឥណទានដែលជាអ្នកសម្របសម្រួលប្រតិបត្តិការគម្រោងឥណទាន
- ផ្នែកទី៣ សម្រាប់ចំណាយការងាររដ្ឋបាលរបស់ក្រុមឥណទាន

## 6. មេរៀន និងបទពិសោធន៍នៃគម្រោងឥណទាន

គម្រោងឥណទានសហមន៍ព្រៃឈើដើម្បីគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងសហគមន៍ព្រៃឈើ របស់សហគមន៍ព្រៃឈើព្រៃក្បាលបី អាចវាយតម្លៃបានថាជាគម្រោងដែលទទួលបានជោគជ័យ ព្រោះៈ

- ទុនឥណទានមានការកើនឡើងពី១០០០ ដល់៤០០០ ក្នុងកំឡុងពេលជាង ២ឆ្នាំ (កំណើនទុននេះកើនឡើង តាមរយៈការវិភាជភាគរយនៃការប្រាក់ឥណទាន និងការចូលរួមវិភាគទានពីភ្ញៀវធ្វើទស្សនកិច្ច)
- គណៈកម្មការមានសមត្ថភាពក្នុងការគ្រប់គ្រងគម្រោង និងធ្វើការកែសម្រួលលក្ខខណ្ឌដោយឆ្លុះបញ្ចាំងទៅលើទិដ្ឋភាពនៃភាពរីកចម្រើន និងតម្រូវការរបស់សមាជិកក្រុម
- សមាជិកសហគមន៍ស្ទើរតែ ១០០% បានចូលរួមក្នុងគម្រោងឥណទាន
- សហគមន៍ព្រៃឈើបានវិភាជថវិកាពីគម្រោងឥណទាន សម្រាប់ល្បាត និងការអនុវត្តសកម្មភាពផ្សេងៗ ដែលបានកំណត់ក្នុងផែនការគ្រប់គ្រងព្រៃសហគមន៍
- គណៈកម្មការមានសមត្ថភាពក្នុងការចែករំលែកបទពិសោធន៍ទៅសហគមន៍ផ្សេងៗ

តាមរយៈភាពជោគជ័យ នៃការអនុវត្តគម្រោងឥណទាននេះ គណៈកម្មការបានលើកឡើងនូវបទពិសោធន៍ និងមេរៀនល្អៗមួយចំនួនមានដូចជាៈ

- ❑ ខ្ចីលុយពីសហគមន៍គឺចូលរួមគ្រប់គ្រង និងអភិវឌ្ឍ ស.ព យើង ព្រោះថា
    - អត្រាការប្រាក់ដូចគ្នានឹងស្ថាប័នហិរញ្ញវត្ថុ ឬទាបជាងឯកជន
    - មិនចំណាយសោហ៊ុយធ្វើដំណើរ
    - ការប្រាក់ ៣០% នឹងប្រើប្រាស់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍព្រៃសហគមន៍
- ❑ គ្រប់គ្រងព្រៃឈើបានល្អទាក់ទាញជំនួយសម្រាប់អភិវឌ្ឍ ស.ព ដល់សហគមន៍ (ជាក់ស្តែងទទួលបានលុយពីប្រធានរដ្ឋបាលព្រៃឈើ ២៥០ដុល្លា និងរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ១០០០ដុល្លា)
- ❑ តម្លាភាព និងអភិបាលកិច្ចនាំមកនូវការជឿទុកចិត្ត និងចូលរួមកាន់តែសកម្មពីសមាជិកសហគមន៍ (ប្រធាន គ.ស.គ ខ្ចីប្រាក់ ត្រូវសងវិញទាំងការ ទាំងដើមដូចសមាជិកដែរ)
- ❑ ត្រូវមានការលះបង់ទើបទទួលបានជោគជ័យ (គណៈកម្មការធ្វើការមិនគិតពីពេលវេលា)
- ❑ អាចឆ្លើយតបទៅនឹងតម្រូវការបន្ទាន់របស់សមាជិក

# 7. ឧបសម្ព័ន្ធ

## *7.1 ឧបសម្ព័ន្ធ ១៖ ពាក្យសុំចូលជាសមាជិកក្រុមឥណទានសហគមន៍ព្រៃឈើ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................................... ភេទ................ អាយុ...........ឆ្នាំ ជាសមាជិកសហគមន៍ព្រៃឈើ.......................................................នៃភូមិ.................................ឃុំ.........................................ស្រុក.........................ខេត្តកំពង់ធំ។

**សូមគោរពជូន**

**លោកប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ**.......................................

កម្មវត្ថុ៖ សំណើសុំចូលជាសមាជិកក្រុមឥណទានសហគមន៍ព្រៃឈើ.................................................។

យោង៖ កិច្ចប្រជុំផ្សព្វផ្សាយគម្រោងឥណទានខ្នាតតូចសហគមន៍ព្រៃឈើ...............................កាលពីថ្ងៃទី.......... ខែ................ឆ្នាំ២០១...........។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ ជាសមាជិកសហគមន៍ព្រៃឈើ មានបំណង និងឆន្ទៈពិតប្រាកដក្នុង ការចូលរួមក្នុងក្រុមឥណទានខ្នាតតូចសហគមន៍ព្រៃឈើ ដើម្បីជួយថែរក្សា ការពារ និងគ្រប់គ្រងធនធាន ព្រៃឈើសហគមន៍ឲ្យមាននិរន្តភាពក្នុងការប្រើប្រាស់ និងសំរាប់កូនចៅជំនាន់ក្រោយ។ សូមសន្យាថា នឹងគោរព និងអនុវត្តតាមលក្ខន្តិកៈនៃក្រុមឥណទានដែលមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសហគមន៍ ព្រៃឈើ និងមានការទទួលស្គាល់ពីអាជ្ញាធរ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាអនុញ្ញាឲ្យខ្ញុំបាទ/នាងខ្ញុំ បានចូលជាសមាជិកក្រុមឥណទានខ្នាតតូចសហគមន៍ព្រៃឈើតាមការស្នើសុំខាងលើ ដោយសេចក្តីអនុគ្រោះ។

**សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។**

ថ្ងៃទី..........ខែ.............ឆ្នាំ២០១.......

ស្នាមមេដៃស្តាំ និងឈ្មោះ

បានឃើញ និង ទទួលស្គាល់

ឈ្មោះខាងលើជាសមាជិកសហគមន៍ព្រៃឈើ.........................ពិតប្រាកដមែន

ថ្ងៃទី.............ខែ..................ឆ្នាំ២០១.............

**ប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ**

បានឃើញ និង ឯកភាព

ថ្ងៃទី.............ខែ...............ឆ្នាំ២០១.....

**មេឃុំ**

*7.2ឧបសម្ព័ន្ធ ២៖ លក្ខន្តិកៈស្តីពីការគ្រប់គ្រងប្រាក់ឥណទានសហគមន៍ព្រៃឈើ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លក្ខន្តិកៈ

# ស្តីពី

# ការគ្រប់គ្រងប្រាក់ឥណទាន
# សហគមន៍ព្រៃឈើ

សហគមន៍ព្រៃឈើព្រៃក្បាលបី

ឆ្នូមិក្បាលបី ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ

**ខែមករា ឆ្នាំ២០១៥**

# លក្ខន្តិកៈស្តីពីការគ្រប់គ្រងប្រាក់ឥណទានសហគមន៍ព្រៃឈើព្រៃក្បាលបី

## ជំពូកទី១
## អំពីគម្រោងឥណទានសហគមន៍ព្រៃឈើ និងគោលបំណង

**ប្រការ១៖** គឺជាគម្រោងដែលផ្តល់ថវិកាសម្រាប់ជាទុនក្នុងការធ្វើឥណទានសហគមន៍ព្រៃឈើ តាមរយៈមូលនិធិអភិវឌ្ឍន៍សហគមន៍ព្រៃឈើ។ ថវិកានេះត្រូវគ្រប់គ្រងដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើក្រោមលក្ខខណ្ឌដែលមានការឯកភាពដឹងឮពីសមាជិកសហគមន៍ព្រៃឈើ និងមានការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន (មេភូមិ និងមេឃុំ)។ សមាជិកសហគមន៍ព្រៃឈើដែលចាប់អារម្មណ៍ចង់ខ្ចីប្រាក់ពីមូលនិធិអភិវឌ្ឍសហគមន៍ព្រៃឈើយកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅត្រូវចូលរួមចងក្រងជាក្រុម និងបោះឆ្នោតជ្រើសតាំងគណៈកម្មការក្រុមឥណទាន និងបង្កើតជាលក្ខន្តិកៈឥណទានសម្រាប់ក្រុមអនុវត្ត។ លក្ខន្តិកៈឥណទាននេះត្រូវមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងមានការទទួលស្គាល់ពីអាជ្ញាធរ ភូមិ ឃុំ។

**ប្រការ២៖** គោលបំណងដើម្បីពង្រឹងស្ថាប័នសហគមន៍ព្រៃឈើរួមចំណែកក្នុងការជួយលើកស្ទួយកម្រិតជីវភាពរស់នៅរបស់សមាជិកសហគមន៍ព្រៃឈើ និងលើកទឹកចិត្តឲ្យមានការចូលរួមអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ប្រកបដោយនិរន្តរភាព។

## ជំពូកទី២
## បទប្បញ្ញត្តិទូទៅ

**ប្រការ៣៖** លក្ខន្តិកៈនេះកំណត់ក្របខណ្ឌនៃការគ្រប់គ្រងគម្រោងឥណទានសហគមន៍ព្រៃឈើនៅសហគមន៍ព្រៃឈើព្រៃក្បាលបី។

**ប្រការ៤៖** ប្រាក់ឥណទាននេះស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ ព្រៃឈើព្រៃក្បាលបី និងស្ថិតក្រោមការចាត់ចែងផ្ទាល់របស់គណៈកម្មការក្រុមឥណទានសហគមន៍ព្រៃឈើ។

## ជំពូកទី ៣
## លក្ខខណ្ឌនៃការសុំចូលជាសមាជិកក្រុមឥណទាន

**ប្រការ៥៖** មានតែជាសមាជិកសហគមន៍ព្រៃឈើព្រៃក្បាលបី នៅក្នុងភូមិក្បាលបី ឃុំទីពោស្រុកសន្ទុក ខេត្តកំពង់ធំតែប៉ុណ្ណោះដែលអាចចូលជាសមាជិកក្រុមឥណទានសហគមន៍ព្រៃឈើបាន។ អ្នកចុះឈ្មោះត្រូវតែជាមេគ្រួសារ និងមានការទទួលស្គាល់ពីគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងមេឃុំសាម៉ី។

**ប្រការ៦៖** សមាជិកក្រុមឥណទានមានកាតព្វកិច្ចចូលរួមរាល់សកម្មភាពអភិវឌ្ឍន៍សហគមន៍ព្រៃឈើ ស្របតាម សកម្មភាពដែលមាននៅក្នុងផែនការគ្រប់គ្រងសហគមន៍ព្រៃឈើព្រៃក្បាលបី និងសកម្មភាពផ្សេងៗទៀត ដែលផ្តួចផ្តើមឡើងដោយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើទាក់ទងទៅនឹងការអភិវឌ្ឍសហគមន៍ព្រៃឈើព្រៃក្បាលបី តាមការអញ្ជើញរបស់គណៈកម្មការ ។

**ប្រការ៧៖** សមាជិកក្រុមឥណទានត្រូវបង់ប្រាក់តំកល់របស់ខ្លួនចូលទៅក្នុងប្រាក់សន្សំនៃក្រុមឥណទានសហគមន៍ចាប់ពី ពីរម៉ឺន(២០០០០)រៀល ដល់ ប្រាំម៉ឺន(៥០០០០)រៀល។

## ជំពូកទី៤
## សិទ្ធិ និងតួនាទីរបស់ក្រុមឥណទាន

**ប្រការ៨៖** គណៈកម្មការក្រុមឥណទានៈ

- ជាអ្នកទទួលខុសត្រូវចំពោះមុខគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ នូវចំនួនទឹកប្រាក់ឥណទានផ្តល់ជូន។
- ជាអ្នកចុះកិច្ចព្រមព្រៀងទទួលប្រាក់ឥណទានពីគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ។
- ជាអ្នកចាត់ចែងប្រាក់ឥណទាន ជូនសមាជិកក្រុមខ្ចី។
- ជាអ្នករាយការណ៍នូវស្ថានភាពប្រាក់ឥណទាន និងបង្វិលប្រាក់ឥណទានជូនគណៈកម្មការ គ្រប់គ្រងសហគមន៍ព្រៃឈើវិញតាមកិច្ចព្រមព្រៀងដែលរួមមានទាំងប្រាក់ដើម និងការប្រាក់។
- គណៈកម្មការក្រុមឥណទានមានសមាជិក៣រូបសំខាន់គឺៈ
  - **ក.ប្រធានក្រុមៈ** ជាអ្នកគ្រប់គ្រងក្រុម ដឹកនាំសមាជិកក្រុមក្នុងអង្គប្រជុំ កោះហៅសមាជិកក្រុមចូលរួមប្រជុំ ត្រួតពិនិត្យសាច់ប្រាក់ក្នុងក្រុម និងតំណាងឲ្យក្រុមទាំងមូល។
  - **ខ.អនុប្រធានក្រុមៈ** ជាជំនួយការឲ្យប្រធានក្រុម និងជាអ្នកគ្រប់គ្រង ដឹកនាំសមាជិកក្នុងអង្គប្រជុំពេលប្រធានអវត្តមាន ជាអ្នកកត់ត្រាបញ្ជីស្មាមក្នុងក្រុម និងជាអ្នកកត់ត្រាកំណត់ហេតុពេលប្រជុំ។
  - **គ.ហិរញ្ញិកៈ** ជាអ្នកគ្រប់គ្រង និងថែរក្សាសាច់ប្រាក់ក្នុងក្រុម និងជាអ្នកកត់ត្រានូវបញ្ជីស្នាមសាច់ប្រាក់ក្នុងក្រុម។ ហិរញ្ញិកក៏ត្រូវបូកសរុប និងប្រកាសទឹកប្រាក់ទាំងអស់ឲ្យសមាជិក និង គណៈកម្មការក្រុមឥណទានដឹងទាំងអស់គ្នាជាកំហិត។

**ប្រការ៩៖** សមាជិកក្រុមគ្រប់ៗរូបត្រូវចូលរួមគោរព និងអនុវត្តតាមការណែនាំរបស់គណៈកម្មការក្រុម និងធានាថាមិនបង្កការស្មុគ្រស្មាញដល់ក្រុមទាំងមូល និងត្រូវមានឆន្ទៈគិតពីផលប្រយោជន៍រួមជាចំបង។

**ប្រការ១០៖** រាល់ឯកសារដែលពាក់ព័ន្ធនឹងដំណើរការបង្កើតក្រុមឥណទានសហគមន៍ព្រៃឈើត្រូវរក្សាទុកក្នុងសហគមន៍មួយច្បាប់ នៅសាលាឃុំមួយច្បាប់ និង សង្កាត់រដ្ឋបាលព្រៃឈើសាមុីមួយច្បាប់ ដើម្បីធានាសុវត្ថិភាព។

**ប្រការ១១៖** គណៈកម្មការក្រុមឥណទានត្រូវធ្វើការផ្លាស់ប្តូររៀងរាល់ ២ឆ្នាំម្តង តាមរយៈការបោះឆ្នោតជ្រើសរើសដោយសមាជិកក្រុម។

សមាជិកក្រុមអាចស្នើសុំការបោះឆ្នោតជ្រើសរើសគណៈកម្មការក្រុមឥណទានមុនអណត្តិបាន ករណីគណៈកម្មការក្រុមឥណទានដំណើរការមិនប្រក្រតី។

សមាជិកគណៈកម្មការក្រុមឥណទានណាម្នាក់ដែលអសកម្ម ឬលាឈប់ពីគណៈកម្មការក្រុមឥណទាន នោះសមាជិកក្រុមនឹងធ្វើការជ្រើសរើសតាមមតិភាគច្រើនមកជំនួសជាបន្ទាន់។

**ប្រការ១២៖** សមាជិកគណៈកម្មការក្រុមឥណទានចាស់ដែលបញ្ចប់អណត្តិ ឬលាឈប់ត្រូវធ្វើបញ្ជីស្នាម និងទូទាត់ឯកសារសាច់ប្រាក់ឲ្យបានចប់សព្វគ្រប់មុននឹងគណៈកម្មការឥណទានថ្មីចាប់ផ្តើម។

**ប្រការ១៣៖** សមាជិកក្រុមត្រូវប្រជុំមួយខែម្តង គឺរៀងរាល់ចុងខែ នាថ្ងៃទី២៨ វេលាម៉ោង៨ព្រឹក។ សមាជិកក្រុមអាចស្នើឲ្យមានការប្រជុំពិសេសផ្សេងៗមុនកំណត់ក្នុងករណីចាំបាច់។

**ប្រការ១៤៖** ការអនុញ្ញាតឲ្យសមាជិកណាម្នាក់ខ្ចីប្រាក់បាន លុះត្រាមានការសម្រេចពីប្រធានគណៈកម្មការក្រុមឥណទានជាមុនសិន និងមានពាក្យសុំខ្ចីប្រាក់ដោយបញ្ជាក់ពីគោលបំណងចំនួនប្រាក់ខ្ចី រយៈពេលខ្ចី និងការធានាសងមកវិញ។

## ជំពូកទី៥
## លក្ខខណ្ឌនៃការសុំឈប់ពីសមាជិកក្រុមឥណទាន

**ប្រការ១៥៖** សមាជិកក្រុមឥណទានសហគមន៍ព្រៃឈើទាំងអស់អាចសុំលាឈប់ពីសមាជិកក្រុមបានលុះត្រាតែសមាជិកនោះមិនមានជំពាក់ប្រាក់ឥណទានពីមុនឬបានសង ប្រាក់គ្រប់ចំនួនដែលខ្លួនបានខ្ចីមកគណៈកម្មការក្រុមឥណទានសហគមន៍ឲ្យរួចរាល់សិនទើបអនុញ្ញាតឲ្យលាឈប់។

**ប្រការ១៦៖** ចំពោះប្រាក់តំកល់ត្រូវប្រគល់ជូនសាមីខ្លួនវិញក្នុងករណីសមាជិកនោះបានដាក់ពាក្យសុំលាឈប់ពីក្រុមឥណទានសហគមន៍ព្រៃឈើ ដូចចែងក្នុងប្រការ១៥។

## ជំពូកទី៦
## ការខ្ចីប្រាក់ និងសងប្រាក់

**ប្រការ១៧៖** រាល់ពេលខ្ចីប្រាក់សមាជិកក្រុមឥណទានត្រូវដាក់ពាក្យសុំខ្ចីប្រាក់ភ្ជាប់ដោយកិច្ចសន្យាជាមួយប្រធានក្រុមឥណទាន។ ក្នុងពាក្យសុំមានភ្ជាប់មកជាមួយនូវប័ណ្ណគ្រួសារ ឬអត្តសញ្ញាណប័ណ្ណថតចម្លង និងប្រកាសនូវទ្រព្យសម្បត្តិមានតម្លៃស្មើ ឬលើសសម្រាប់លក់សង ក្នុងករណីដែលមិនអាចរកប្រាក់សងបានតាមពេលកំណត់ ។

**ប្រការ១៨៖** ប្រសិនបើសមាជិក និងគណៈកម្មការក្រុមណាម្នាក់ចង់ខ្ចីប្រាក់អាចជូនដំណឹងទៅ គណៈកម្មការក្រុមនៅថ្ងៃណាក៏បានប៉ុន្តែចំពោះការផ្តល់ប្រាក់ឲ្យខ្ចីត្រូវសម្រេចលើសមាជិកទាំងអស់ និងគណៈកម្មការនៅថ្ងៃប្រជុំជាកំណត់។ ក្នុងករណីតម្រូវការបន្ទាន់ដែលមានមូលហេតុច្បាស់លាស់ និងមានការដឹងលឺពីសមាជិកគណៈកម្មការក្រុម សមាជិកនោះអាចសុំខ្ចីមុនពេលកំណត់បាន។

**ប្រការ១៩៖** សមាជិកម្នាក់ៗមានសិទ្ធិខ្ចីប្រាក់ឥណទាននេះក្នុងរយៈពេល ៣(បី)ខែយ៉ាងយូរ ដោយគិតចាប់ពីថ្ងៃដែលបានទទួលបានប្រាក់កម្ចី។ ក្នុងករណីសមាជិកណាម្នាក់ប្រើប្រាស់ថវិកាដែលបានខ្ចីស្របទៅតាមគោលបំណង ដែលគោលបំណងត្រូវចំណាយពេលយូរ ហើយដោយមានការឯកភាពពីក្រុមផងដែរនោះ សមាជិកអាចបន្តឲ្យខ្ចីរយៈពេល ២ខែបន្ថែមទៀត។

**ប្រការ២០៖** សមាជិកក្រុមដែលមានពាក់ព័ន្ធ នឹងការខ្ចីប្រាក់ច្រើនពីអង្គការ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ សមាជិកនោះមិនអនុញ្ញាតឲ្យខ្ចីប្រាក់ក្នុងក្រុមឥណទានបានឡើយ។ ក្នុងករណីមានការពាក់ព័ន្ធដូច្នេះ សមាជិកនោះត្រូវដោះស្រាយបញ្ហាដែលពាក់ព័ន្ធឲ្យអស់ជាមុនសិនទើបអនុញ្ញាតឲ្យខ្ចីប្រាក់ពីក្រុមបាន។

**ប្រការ២១៖** ប្រាក់កម្ចីត្រូវសងត្រឡប់មកវិញតាមពីររូបភាពដោយយោងតាមសំណូមពរពីអ្នកខ្ចីៈ

១.ការបង់តែការប្រាក់ប្រចាំខែ និងសងប្រាក់កម្ចីសរុបនៅចុងវគ្គ

២.បង់រំលោះប្រចាំខែនូវប្រាក់ដើម និងការប្រាក់ឲ្យគ្រប់ចំនួនទៅតាមពេលវេលាដែលបានកំណត់ក្នុងកិច្ចសន្យានៃការខ្ចីប្រាក់។

**ប្រការ២២៖** ប្រាក់កម្ចីឥណទានសហគមន៍មានអត្រាការប្រាក់ប្រចាំខែបីភាគរយ(៣%)នៃប្រាក់សរុបដែលសមាជិកបានខ្ចី។

**ប្រការ២៣៖** សមាជិកក្រុមឥណទានអាចខ្ចីប្រាក់ពីឥណទានសហគមន៍បាន ចាប់ពី ដប់ម៉ឺន(១០០០០០) រៀល ដល់ហាសិបម៉ឺន(៥០០០០០) រៀល។

**ប្រការ២៤៖** សមាជិកក្រុមឥណទានដែលខ្ចីប្រាក់ត្រូវបញ្ជាក់ពីគោលបំណងឲ្យបានច្បាស់លាស់ និងត្រូវទូទាត់ប្រាក់ជំពាក់ចាស់សិន ទើបអនុញ្ញាតិឲ្យខ្ចីបន្ត។

## ជំពូកទី៧
## ការពិន័យ

**ប្រការ២៥៖** អ្នកមិនគោរពតាមកិច្ចសន្យាខ្ចីប្រាក់ មិនសងប្រាក់ ឬសងប្រាក់មិនទាន់ពេលវេលា ត្រូវពិន័យដោយគិតដូចតទៅ៖

ក.កម្ចីប្រាក់ត្រឹមសាមសិបម៉ឺន(៣០០០០០)រៀលចុះត្រូវផាកពិន័យមួយពាន់ប្រាំរយ(១៥០០)រៀលក្នុងមួយថ្ងៃ។

ខ.កម្ចីប្រាក់ចាប់ពីសាមសិបមួយម៉ឺន(៣១០,០០០)រៀលឡើងទៅត្រូវផាកពិន័យ បីពាន់(៣០០០)រៀលក្នុងមួយថ្ងៃ។

គ.ស្នើសុំអន្តរាគមន៍ពីអាជ្ញាធរឃុំ ដើម្បីបង្ខំឲ្យលក់ទ្រព្យសម្បត្តិមានតំលៃដែលបានប្រកាសពេលស្នើសុំខ្ចីប្រាក់សម្រាប់សងប្រាក់កម្ចី ការប្រាក់ និងប្រាក់ពិន័យដោយមានការអន្តរាគមន៍ពីអាជ្ញាធរឃុំសាម៉ី។

**ប្រការ២៦៖** ប្រសិនបើសមាជិកក្រុមគណៈទានណាម្នាក់អវត្តមានក្នុងការងារសហគមន៍៖

១. ការងារក្នុងព្រៃសហគមន៍ត្រូវពិន័យ ប្រាំបីពាន់(៨០០០)រៀល ក្នុងការអវត្តមានម្តង។

២. ការងារក្នុងភូមិត្រូវពិន័យ បួនពាន់(៤០០០)រៀល ក្នុងការអវត្តមានម្តង។

៣. ក្នុងករណីសមាជិកណាម្នាក់អវត្តមានដោយ មានហេតុផលច្បាស់លាស់ និងមានការដឹងលឺពីសមាជិកក្រុមផងដែរនោះ សមាជិកនោះត្រូវបានលើកលែងពីការពិន័យ។

## ជំពូកទី៨
## ការបែងចែកផលប្រយោជន៍

**ប្រការ២៧៖** ប្រាក់ តំកល់របស់សមាជិកម្នាក់ៗនឹងទទួលបានអត្រាការប្រាក់ដប់ភាគរយក្នុងមួយឆ្នាំ។

**ប្រការ២៨៖** ការប្រាក់សរុបដែលទទួលបានពីការចងការប្រាក់ត្រូវបែងចែកជា៣ផ្នែកដូចតទៅ៖

ក. ចិតសិបភាគរយ(៧០%)សម្រាប់ដាក់ចូលទៅក្នុងមូលនិធិអភិវឌ្ឍសហគមន៍ព្រៃឈើ អត្រាការប្រាក់នេះត្រូវបែងចែកបន្តជាពីរចំណែកទៀតគឺពាក់កណ្តាលត្រូវបញ្ចូលទៅការបង្កើនទុនឲ្យខ្ចី និងពាក់កណ្តាលសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍។

ខ. ម្ភៃភាគរយ(២០%)ជាភាគលាភរបស់គណៈកម្មការក្រុមគណៈទាន។

គ. ដប់ភាគរយ(១០%)សម្រាប់ថ្លៃសេវារដ្ឋបាលរបស់គណៈកម្មការក្រុមគណៈទាន។

## ជំពូកទី៩
## ការកែប្រែលក្ខន្តិកៈ និងការរំសាយក្រុម

**ប្រការ២៩៖** លក្ខន្តិកៈនេះនឹងកែសម្រួលឡើងវិញ ក្នុងករណីមានការចាំបាច់និងស្របតាមការរីកចម្រើនរបស់ក្រុម។

ប្រការ៣០៖ ករណីក្រុមត្រូវបានរំសាយដោយសមាជិកខ្លួនឯងប្រាក់ឥណទានសហគមន៍ទាំងអស់ត្រូវបង្វិលបញ្ចូលទៅក្នុងខ្ទង់ថវិកាមូលនិធិអភិវឌ្ឍសហគមន៍វិញ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

ប្រការ៣១៖ សមាជិកក្រុមឥណទានគ្រប់រូប និងគណៈកម្មការក្រុមឥណទានត្រូវអនុវត្តលក្ខន្តិកៈនេះតាមភារៈកិច្ចរៀងៗខ្លួន។ គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ និងគណៈកម្មការក្រុមឥណទានត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់សមាជិកក្នុងសហគមន៍។

ប្រការ៣២៖ លក្ខន្តិកៈស្តីពីការគ្រប់គ្រងប្រាក់ឥណទានសហគមន៍ព្រៃឈើនេះមានប្រសិទ្ធភាព អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភូមិក្បាលបី,ថ្ងៃទី២២ ខែ០១ ឆ្នាំ២០១៥
ប្រធានគណៈកម្មការក្រុមឥណទាន

បានឃើញ និងឯកភាព
ថ្ងៃទី២២ ខែ០១ ឆ្នាំ២០១៥
ប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ

បានឃើញ និងឯកភាព
ថ្ងៃទី២២ ខែ០១ ឆ្នាំ២០១៥
មេភូមិក្បាលបី

លេខ៖ ៥៥/២០១៥
បានឃើញ និងឯកភាព
ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៥
មេឃុំ

## *7.3 ឧបសម្ព័ន្ធ៣៖ ទម្រង់កិច្ចព្រមព្រៀងខ្ចីប្រាក់*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាងគណៈកម្មការក្រុមឥណទានសហគមន៍ព្រៃឈើ (ភាគី ក)**
**និង**
**គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ................................(ភាគី ខ)**

ភាគីទាំងពីរព្រមព្រៀងគ្នាក្នុងការប្រើប្រាស់ប្រាក់ឥណទានសហគមន៍ព្រៃឈើ.........................................ដោយគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ៖

**ភាគី ក:** បានខ្ចីប្រាក់ចំនួនៈ...............................( ជាអក្សរ...................................................................)។ ក្នុងគោលបំណងប្រើប្រាស់ប្រាក់កម្ចីនេះ ឲ្យសមាជិកក្រុមរបស់ខ្លួន ចំនួន .............នាក់ ខ្ចីបន្តដែលមានអត្រាការប្រាក់ចំនួន ៣ % ក្នុង១ខែ។

**ភាគី ក:** ត្រូវអនុវត្តតាមប្រការនានាដូចមានចែងក្នុងលក្ខន្តិកៈស្តីពីការគ្រប់គ្រងប្រាក់ឥណទានសហគមន៍ព្រៃឈើ

**ភាគី ខ:** បានឯកភាពផ្តល់ប្រាក់កម្ចី ចំនួនដូចខាងលើ ឲ្យ **ភាគី ក** ប្រើប្រាស់ ដោយទទួលផលប្រយោជន៍ដូចមានចែងក្នុងលក្ខន្តិកៈស្តីពីការគ្រប់គ្រងប្រាក់ឥណទានសហគមន៍ព្រៃឈើ។

**រយៈពេលខ្ចី:**ភាគីទាំងពីរបានឯកភាពលើរយៈពេល..............ខែ ដោយគិតចាប់ ពីថ្ងៃទី...........ខែ.......... ឆ្នាំ..............ដល់ថ្ងៃទី...........ខែ.........ឆ្នាំ.................។ ផុតកំណត់នេះ **ភាគី ក** ត្រូវបង្វិលប្រាក់ដើម និងការប្រាក់ដែលទទួលបានពីប្រតិបត្តិការកម្ចីប្រាក់ជូន **ភាគី ខ** វិញតាមការឯកភាពក្នុងលក្ខន្តិកៈស្តីពីការគ្រប់គ្រងប្រាក់ឥណទានសហគមន៍ព្រៃឈើ។

ដើម្បីជាសក្ខីភាពនៃការព្រមព្រៀងគ្នា ភាគីទាំងពីរបានផ្តិតមេដៃស្តាំជាភស្តុតាង ក្នុងផ្លូវច្បាប់។

ថ្ងៃទី............ខែ...........ឆ្នាំ.............

| | |
|---|---|
| **គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ....................** | **គណៈកម្មការក្រុមឥណទាន** |
| (**ភាគី ខ**) | (**ភាគី ក**) |

## 7.4 ឧបសម្ព័ន្ធ ៤៖ ទម្រង់សំណើខ្ចីប្រាក់របស់សមាជិក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមឥណទាន**
**សហគមន៍ព្រៃឈើ**............................ ថ្ងៃទី............ខែ............ឆ្នាំ.............

### កិច្ចសន្យាខ្ចីប្រាក់

ឈ្មោះអ្នកខ្ចី (ប្តី)៖........................................អាយុ:..........ឆ្នាំលេខអត្តសញ្ញាណប័ណ្ណ:.........................................
ឈ្មោះអ្នកខ្ចី(ប្រពន្ធ)៖.........................................អាយុ:.........ឆ្នាំ លេខអត្តសញ្ញាណប័ណ្ណ:..................................
ទីលំនៅបច្ចុប្បន្ន ភូមិ..............................ឃុំ..................................ស្រុក........................................ខេត្តកំពង់ធំ។
ចំនួនទឹកប្រាក់ដែលខ្ចី:..........................................(សរសេរជាអក្សរ.........................................................)។
គោលបំណងនៃការខ្ចី:.........................................................................................................។
រយៈពេលខ្ចី:................ខែ ពីថ្ងៃទី...........ខែ..........ឆ្នាំ................ដល់ថ្ងៃទី..........ខែ..........ឆ្នាំ.................។
ការប្រាក់....................ភាគរយក្នុងមួយខែ ☐ បង់រំលោះប្រចាំខែ ☐ បង់ការប្រចាំខែ

វត្ថុបញ្ចាំ.........................................................................................................................។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាថា នឹងសងប្រាក់មកវិញឲ្យគ្រប់ចំនួនទាំងការទាំងដើម តាមការកំណត់នៅក្នុងកិច្ចសន្យានេះ ដោយមិនមានការកែប្រែអ្វីឡើយ។ ប្រសិនបើ ខ្ញុំបាទ/នាងខ្ញុំមិនបានបង់ប្រាក់តាមការកំណត់នៅក្នុង កិច្ចសន្យានេះទេ សូមឲ្យគណៈកម្មការក្រុមឥណទានសហគមន៍ព្រៃឈើព្រៃក្បាលបី ធ្វើការដាក់ពិន័យតាមលក្ខន្តិកៈក្រុមឥណទានសហគមន៍ព្រៃឈើ។

ឈ្មោះ និងស្នាមមេដៃស្តាំអ្នកខ្ចីប្រាក់

សាក្សី

បានឃើញ និងទទួលស្គាល់
ប្រធានក្រុមឥណទាន

បានឃើញ និងទទួលស្គាល់
ប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ

## 7.5 ឧបសម្ព័ន្ធ ៥៖ តារាងកាលវិភាគបង់ប្រាក់ប្រចាំខែ

### តារាងកាលវិភាគបង់ការប្រាក់ប្រចាំខែ

ថ្ងៃទី..........ខែ............ឆ្នាំ................

ឈ្មោះអ្នកខ្ចីប្រាក់:......................................ភេទ............អាយុ..............ឆ្នាំ។ ទីលំនៅបច្ចុប្បន្នរស់នៅក្នុង ភូមិ........................ឃុំ.............................ស្រុក..........................ខេត្តកំពង់ធំ។

រយៈពេលខ្ចី:..................ខែ     របៀបបង់ប្រាក់: បង់ការប្រចាំខែ ☐     បង់រំលោះប្រចាំខែ ☐

ប្រាក់ដើមដែលបានខ្ចី:..........................................រៀល     អត្រាការប្រាក់:...............ភាគរយក្នុងមួយខែ

| ខែ | ថ្ងៃ/ខែ/ឆ្នាំ | ប្រាក់ដើមត្រូវបង់ | ការប្រាក់ត្រូវបង់ | សរុបប្រាក់ត្រូវបង់ | ប្រាក់ដើមនៅជំពាក់ | ស្នាមមេដៃអ្នកសងប្រាក់ | ហត្ថលេខាហិរញ្ញិក |
|---|---|---|---|---|---|---|---|
| ទី១ | ........./........../........... | | | | | | |
| ទី២ | ........./........../........... | | | | | | |
| ទី៣ | ........./........../........... | | | | | | |
| ទី៤ | ........./........../........... | | | | | | |
| ទី៥ | ........./........../........... | | | | | | |
| សរុប | | | | | | | |

## *7.6 ឧបសម្ព័ន្ធ ៦៖ សៀវភៅកត់ត្រាការខ្ចីប្រាក់*

សៀវភៅកត់ត្រា ការខ្ចីប្រាក់ សងប្រាក់ និងប្រាក់ពិន័យ

ការប្រជុំលើកទី.......                                                                  ថ្ងៃទី..........................

| ល.រ | ឈ្មោះ | ប្រាក់ដើមបានខ្ចី | ប្រាក់បានសង | | ប្រាក់ពិន័យ | ប្រាក់ដើមនៅជំពាក់ | ថ្ងៃ/ខែ/ឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប្រាក់ដើម | ប្រាក់ការ | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |
| ២៧ | | | | | | | |
| ២៨ | | | | | | | |
| ២៩ | | | | | | | |
| ៣០ | | | | | | | |
| ៣១ | | | | | | | |
| ៣២ | | | | | | | |
| ៣៣ | | | | | | | |
| ៣៤ | | | | | | | |
| ៣៥ | | | | | | | |
| ៣៦ | | | | | | | |
| ៣៧ | | | | | | | |
| ៣៨ | | | | | | | |
| ៣៩ | | | | | | | |
| ៤០ | | | | | | | |
| ៤១ | | | | | | | |
| សរុប | | | | | | | |

## 7.7 ឧបសម្ព័ន្ធ ៧៖ សៀវភៅបេឡា

# សៀវភៅបេឡាកត់ត្រាចំណូល-ចំណាយ

សំរាប់ខែ..........ឆ្នាំ ២០....

| កាលបរិច្ឆេទ | លេខប័ណ្ណ<br>/វិក័យប័ត្រ | បរិយាយ(ចំណូល/ចំណាយ) | ប្រាក់ទទួលបាន<br>(រៀល) | ប្រាក់បានចំណាយ<br>(រៀល) | ប្រាក់នៅសល់<br>(រៀល) | ហត្ថលេខា |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | សរុប (ចំណូល និងចំណាយ) | | | | |
| | | | | ប្រាក់នៅសល់ក្នុងដៃជាក់ស្តែង | | |

ប្រធានក្រុម ................................

ហិរញ្ញឹក ....................................

## *7.8 ឧបសម្ព័ន្ធ ៨៖ ទម្រង់របាយការណ៍ហិរញ្ញវត្ថុ*

ក្រុមគណទានសហគមន៍ព្រៃឈើ................................

របាយការណ៍ព័ត៌មានហិរញ្ញវត្ថុ

ត្រឹមថ្ងៃទី.......... ខែ............... ឆ្នាំ២០....

ឈ្មោះគំរោង: ..................................................................

ម្ចាស់ជំនួយ: ..................................................................

| **ល.រ** | | **បរិយាយ** | **ចំនួនទឹកប្រាក់** |
|---|---|---|---|
| ១ | | ចំនួនប្រាក់នៅសល់ពីខែមុន | |
| ២ | + | សរុបចំនួនសាច់ប្រាក់បានផ្ទេរចូលក្រុមគិតត្រឹមថ្ងៃនេះ | |
| ៣ | _ | សរុបចំណាយជាក់ស្តែងគិតត្រឹមថ្ងៃនេះ | |
| | | **សរុបសាច់ប្រាក់នៅសល់គិតត្រឹមខែនេះ:** | |

**អនុម័តដោយ** **រៀបចំដោយ**